# ពិធីសារតាមចិត្តជ្រើសរើសជាប់នឹងអនុសញ្ញាស្តីពីសិទ្ធិកុមារ
# ពាក់ព័ន្ធនឹងការចូលរួមរបស់កុមារក្នុងជម្លោះប្រដាប់អាវុធ

អនុម័តនិងបើកឱ្យចុះហត្ថលេខា ឱ្យសច្ចាប័ននិងចូលជាសមាជិក
តាមសេចក្តីសម្រេចចិត្តលេខ A/RES/៥៤/២៦៣ ចុះថ្ងៃទី ២៥ ខែឧសភា ឆ្នាំ ២០០០
របស់មហាសន្និបាតអង្គការសហប្រជាជាតិ

**ចូលជាធរមាននៅថ្ងៃទី ១២ ខែកុម្ភៈ ឆ្នាំ ២០០២ ស្របតាមមាត្រា ១០**

***រដ្ឋជាភាគីនៃពិធីសារនេះ :***

*ត្រូវបានលើកទឹកចិត្ត* ដោយការគាំទ្រដ៏ច្រើនលើសលប់ចំពោះអនុសញ្ញាស្តីពីសិទ្ធិកុមារ ដែលបង្ហាញឃើញនូវការសន្យាទូទៅ ក្នុងការខិតខំលើកស្ទួយ និងការពារសិទ្ធិកុមារ ។

*ប្រកាសបញ្ជាក់ជាថ្មីថា* សិទ្ធិកុមារត្រូវការនូវការការពារពិសេស និង*អំពាវនាវសុំឱ្យ* បន្តលើកកំពស់ស្ថានភាពកុមារ ដោយគ្មានការប្រកាន់បែងចែក និងឱ្យមានការអភិវឌ្ឍន៍ និងការអប់រំដល់កុមារ ក្នុងល័ក្ខខ័ណ្ឌសន្តិភាព និងសន្តិសុខ ។

*ត្រូវបានរំខាន* ដោយឥទ្ធិពលនៃជម្លោះប្រដាប់អាវុធ ដែលរាលដាលនិងធ្វើឱ្យខូចប្រយោជន៍ដល់កុមារ និងដោយផលវិបាករយៈពេលវែងសម្រាប់សន្តិភាព សន្តិសុខ និងការអភិវឌ្ឍន៍ស្ថិតស្ថេរ ។

*ផ្តន្ទាទោស* ការដាក់កុមារជាមុខសញ្ញាក្នុងស្ថានភាពនៃជម្លោះប្រដាប់អាវុធ និងការវាយប្រហារត្រង់ៗ លើទីកន្លែងដែលការពារក្រោមច្បាប់អន្តរជាតិ រាប់ទាំងទីកន្លែងដែលជាទូទៅមានវត្តមានកុមារ មានជាអាទិ៍ សាលារៀន និងមន្ទីរពេទ្យ ។

*កត់សំគាល់* ការអនុម័តលក្ខន្តិកៈក្រុងរ៉ូមស្តីពីការតុលាការឧក្រិដ្ឋកម្មអន្តរជាតិ និងជាពិសេស ការរាប់បញ្ចូលជាបទឧក្រិដ្ឋសង្គ្រាមនៅក្នុងលក្ខន្តិកៈនូវការកេណ្ឌ ឬចុះបញ្ជីជ្រើសរើសកុមារក្រោមអាយុ ១៥ ឆ្នាំ ឱ្យធ្វើទាហាន ឬឱ្យចូលរួមបង្កអរិភាពយ៉ាងសកម្ម ក្នុងជម្លោះប្រដាប់អាវុធ ទាំងអន្តរជាតិ ទាំងមិនមែនអន្តរជាតិ ។

*យល់ឃើញថា* ដើម្បីពង្រឹងបន្ថែម នូវការអនុវត្តសិទ្ធិដែលទទួលស្គាល់ក្នុងអនុសញ្ញាស្តីពីសិទ្ធិកុមារ គឺចាំបាច់ត្រូវបង្កើនការការពារកុមារ មិនឱ្យចូលពាក់ព័ន្ធក្នុងជម្លោះប្រដាប់អាវុធ ។

*កត់សំគាល់ឃើញថា* មាត្រា ១ នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ បញ្ជាក់ច្បាស់លាស់ថា សម្រាប់គោលបំណងនៃអនុសញ្ញា កុមារគឺជាមនុស្សមានអាយុក្រោម ១៨ ឆ្នាំ លើកលែងតែក្រោមច្បាប់ដែលអនុវត្តចំពោះកុមារ កំណត់អំពីនីតិភាពទាបជាងនេះ ។

*ជឿជាក់ថា* ពិធីសារតាមចិត្តជ្រើសរើសមួយជាប់នឹងអនុសញ្ញានេះ ដែលកំណត់អាយុមនុស្ស ដែលអាចជ្រើសរើសឱ្យចូលបម្រើក្នុងកងកម្លាំងប្រដាប់អាវុធ និងចូលរួមក្នុងអរិភាព នឹងរួមចំណែកជាក់ស្តែងក្នុងការអនុវត្តគោលការណ៍ដែលត្រូវគិតគូរជាចម្បង ដល់ផលប្រយោជន៍ល្អបំផុតរបស់កុមារ នៅគ្រប់សេចក្តីសម្រេចដែលពាក់ព័ន្ធនឹងកុមារ ។

*កត់សំគាល់ឃើញថា* សន្និសីទអន្តរជាតិលើកទី ២៦ នៃកាកបាទក្រហម និងអឌ្ឍច័ន្ទក្រហម ក្នុងខែធ្នូ ឆ្នាំ១៩៩៥ បានធ្វើអនុសាសន៍ដែលមានជាអាទិ៍ថា ភាគីនៃជម្លោះ ត្រូវចាត់វាល់វិធានការដែលអាចធ្វើទៅបាន ដើម្បីធានាមិនឱ្យកុមារអាយុក្រោម ១៨ ឆ្នាំ ចូលរួមក្នុងអរិភាព ។

*ស្វាគមន៍* ការអនុម័តជាឯកច្ឆ័ន្ទ ក្នុងខែ មិថុនា ឆ្នាំ១៩៩៩ ដោយអង្គការពលកម្មអន្តរជាតិ (**ILO**) នូវអនុសញ្ញាលេខ ១៨២ ស្តីពីការហាមប្រាម និងការចាត់វិធានការបន្ទាន់ ដើម្បីលុបបំបាត់ទម្រង់អាក្រក់បំផុតនៃពលកម្មកុមារ ដែលមានជាអាទិ៍ ការហាមឃាត់ការជ្រើសរើសដោយការបង្ខិតបង្ខំ ឬដោយការដាក់ជាកាតព្វកិច្ច ឱ្យកុមារចូលធ្វើទាហាន ដើម្បីប្រើប្រាស់ក្នុងជម្លោះប្រដាប់អាវុធ ។

*ផ្តន្ទាទោស រួមដោយកង្វល់ធ្ងន់ធ្ងរបំផុត* ចំពោះការជ្រើសរើស ការហ្វឹកហ្វឺន និងការប្រើប្រាស់កុមារក្នុងដែនដីជាតិ ឬក្រៅដែនដីជាតិ នៅក្នុងអរិភាពបង្កដោយក្រុមប្រដាប់អាវុធ ផ្សេងពីកងកម្លាំងប្រដាប់អាវុធរបស់រដ្ឋ និង*ទទួលស្គាល់* តួនាទីរបស់ជនដែលជ្រើសរើស ហ្វឹកហ្វឺន និងប្រើប្រាស់កុមារ នៅក្នុងគោលដៅខាងលើនេះ ។

*រំលឹកឡើងវិញ* នូវកាតព្វកិច្ចរបស់ភាគីនីមួយៗនៃជម្លោះប្រដាប់អាវុធ ក្នុងការអនុវត្តបទបញ្ញត្តិនៃច្បាប់មនុស្សធម៌អន្តរជាតិ ។

*សង្កត់ធ្ងន់ថា* ពិធីសារនេះ មិនប៉ះពាល់ដល់គោលបំណង និងគោលការណ៍ ដូចមានកំណត់ក្នុងធម្មនុញ្ញសហប្រជាជាតិ រួមមានមាត្រា ៥១ ផង និងបទដ្ឋាននានានៃច្បាប់មនុស្សធម៌អន្តរជាតិឡើយ ។

*ចងចាំថា* ល័ក្ខខ័ណ្ឌសន្តិភាព និងសន្តិសុខ ដែលផ្អែកលើការគោរពទាំងស្រុងនូវគោលបំណង និងគោលការណ៍ ដូចបានកំណត់ក្នុងធម្មនុញ្ញ និង*ចងចាំថា* ការអនុវត្តលិខិតុបករណ៍សិទ្ធិមនុស្សដែលពាក់ព័ន្ធ គឺមិនអាចខ្វះបានឡើយ ដើម្បីការពារកុមារឱ្យបានទាំងស្រុង ជាពិសេស អំឡុងពេលមានជម្លោះប្រដាប់អាវុធ និងមានការកាន់កាប់ដោយបរទេស ។

*ទទួលស្គាល់* សេចក្តីត្រូវការពិសេសរបស់កុមារ ដែលជាពិសេស ងាយទទួលរងគ្រោះដោយសារការជ្រើសរើស ឬប្រើប្រាស់នៅក្នុងអរិភាព ផ្ទុយនឹងពិធីសារនេះ ដោយហេតុមកពីស្ថានភាពសេដ្ឋកិច្ច ឬភេទ ។

*ដឹងអំពី* ភាពចាំបាច់ ដើម្បីពិនិត្យពិចារណារកមូលហេតុជាឫសគល់ខាងសេដ្ឋកិច្ច សង្គមកិច្ច និងនយោបាយ ក្នុងការធ្វើឱ្យកុមារពាក់ព័ន្ធក្នុងជម្លោះប្រដាប់អាវុធ ។

*មានជំនឿ* លើភាពចាំបាច់ដើម្បីពង្រឹងសហប្រតិបត្តិការអន្តរជាតិ ក្នុងការអនុវត្តពិធីសារនេះ ព្រមទាំងការស្តារសម្បទាខាងផ្លូវរាងកាយ និងផ្លូវចិត្ត និងការបញ្ចូលទៅក្នុងសង្គមវិញនូវកុមារដែលជាជនរងគ្រោះនៃជម្លោះប្រដាប់អាវុធ ។

*លើកទឹកចិត្ត* ដល់ការចូលរួមរបស់សហគមន៍ ជាពិសេស កុមារ និងកុមាររងគ្រោះ ក្នុងការផ្សព្វផ្សាយព័ត៌មាន និងកម្មវិធីអប់រំស្តីពីការអនុវត្តពិធីសារនេះ ។

***បានព្រមព្រៀងគ្នាដូចតទៅ :***

## **មាត្រា ១**

រដ្ឋភាគី ត្រូវចាត់វាល់វិធានការតាមដែលអាចធ្វើបាន ដើម្បីធានាថា សមាជិកកងកម្លាំងប្រដាប់អាវុធរបស់ខ្លួន ដែលអាយុមិនគ្រប់ ១៨ ឆ្នាំ មិនចូលរួមដោយផ្ទាល់ ក្នុងអរិភាពឡើយ ។

## **មាត្រា ២**

រដ្ឋភាគី ត្រូវធានាថា មនុស្សមិនគ្រប់អាយុ ១៨ ឆ្នាំ មិនត្រូវបានជ្រើសរើសឱ្យចូលក្នុងកងកម្លាំងប្រដាប់អាវុធរបស់រដ្ឋជាដាច់ខាត ។

## មាត្រា ៣

១. រដ្ឋភាគី ត្រូវតំឡើងអាយុអប្បបរិមា សម្រាប់ការជ្រើសរើសអ្នកស្ម័គ្រចិត្តចូលបម្រើកងកម្លាំងប្រដាប់អាវុធជាតិរបស់ខ្លួន ឱ្យខ្ពស់ជាងអាយុដែលបានកំណត់ក្នុងមាត្រា ៣៨ កថាខណ្ឌ ៣ នៃអនុសញ្ញាស្ដីពីសិទ្ធិកុមារ ដោយគិតដល់គោលការណ៍ដែលមានកំណត់ក្នុងមាត្រានោះ និងដោយទទួលស្គាល់ថា ក្រោមអនុសញ្ញានោះ មនុស្សដែលមានអាយុក្រោម ១៨ ឆ្នាំ មានសិទ្ធិទទួលបាននូវការការពារពិសេស ។

២. រដ្ឋភាគីនីមួយៗ នៅពេលឱ្យសច្ចាប័ន ឬចូលជាសមាជិកនៃពិធីសារនេះ ត្រូវតំកល់សេចក្ដីប្រកាសខ្ជាប់មួយ ស្ដីពីការកំណត់អាយុអប្បបរមា ដែលអនុញ្ញាតឱ្យជ្រើសរើសអ្នកស្ម័គ្រចិត្ត ចូលបម្រើក្នុងកងកម្លាំងប្រដាប់អាវុធជាតិរបស់ខ្លួន និងត្រូវតំកល់សេចក្ដីពណ៌នាអំពីវិធានការការពារ ដែលរដ្ឋភាគីបានអនុម័ត ដើម្បីធានាថា មិនមានការជ្រើសរើសដោយបង្ខិតបង្ខំ ។

៣. រដ្ឋភាគី ដែលអនុញ្ញាតឱ្យជ្រើសរើសអ្នកស្ម័គ្រចិត្ត មានអាយុក្រោម ១៨ ឆ្នាំ ឱ្យចូលបម្រើក្នុងកងកម្លាំងប្រដាប់អាវុធជាតិរបស់ខ្លួន ត្រូវសន្យាធានាឱ្យបានជាអប្បបរមាថា :

(ក) ការជ្រើសរើស ធ្វើតាមការស្ម័គ្រចិត្តពិតប្រាកដ ។

(ខ) ការជ្រើសរើស ធ្វើឡើងដោយមានការយល់ព្រមដឹងឮពីឳពុកម្ដាយ ឬអាណាព្យាបាលស្របច្បាប់របស់ជននោះ ។

(គ) ជននោះ ត្រូវទទួលបានព័ត៌មានពេញលេញស្ដីពីករណីយកិច្ចចូលរួមបម្រើកងទ័ព ។

(ឃ) ជននោះ ត្រូវផ្ដល់ភស្តុតាងសមស្របអំពីអាយុរបស់ខ្លួន មុនទទួលឱ្យចូលបម្រើកងទ័ពជាតិ ។

៤. រដ្ឋភាគីនីមួយៗ អាចពង្រឹងសេចក្ដីប្រកាសរបស់ខ្លួនបានគ្រប់ពេល ដោយជូនដំណឹងអំពីកិច្ចការនេះ ទៅអគ្គលេខាធិការអង្គការសហប្រជាជាតិ ហើយអគ្គលេខាធិការ ត្រូវជូនដំណឹងអំពីការពង្រឹងនេះទៅរដ្ឋភាគីទាំងអស់ ។ ការជូនដំណឹងនេះ មានអនុភាពចាប់ពីកាលបរិច្ឆេទ ដែលអគ្គលេខាធិការអង្គការសហប្រជាជាតិ ទទួលបាននូវសេចក្ដីជូនដំណឹងនោះ ។

៥. ការតម្រូវឱ្យតំឡើងអាយុក្នុងកថាខ័ណ្ឌ ១ នៃមាត្រានេះ មិនអនុវត្តចំពោះគ្រឹះស្ថានសិក្សា ដែលស្ថិតក្រោមការគ្រប់គ្រង ឬការត្រួតពិនិត្យនៃកងកម្លាំងប្រដាប់អាវុធនៃរដ្ឋភាគីឡើយ ដោយប្រកាន់ខ្ជាប់តាមមាត្រា ២៨ និងមាត្រា ២៩ នៃអនុសញ្ញាស្ដីពីសិទ្ធិកុមារ ។

## មាត្រា ៤

១. ក្រុមប្រដាប់អាវុធ ក្រៅពីកងកម្លាំងប្រដាប់អាវុធរបស់រដ្ឋ ទោះស្ថិតក្នុងកាលៈទេសៈណាក៏ដោយ មិនត្រូវជ្រើសរើស ឬប្រើប្រាស់មនុស្សអាយុក្រោម ១៨ ឆ្នាំ ក្នុងអរិភាពឡើយ ។

២. រដ្ឋភាគី ត្រូវចាត់រាល់វិធានការតាមដែលអាចធ្វើបាន ដើម្បីទប់ស្កាត់ការជ្រើសរើស និងការប្រើបែបនេះ និងអនុម័តវិធានការខាងផ្លូវច្បាប់ដែលចាំបាច់ ដើម្បីហាមឃាត់ និងដាក់ជាបទព្រហ្មទ័ណ្ឌចំពោះការប្រព្រឹត្តបែបនេះ ។

៣. ការអនុវត្តមាត្រានេះ មិនប៉ះពាល់ឋានៈខាងផ្លូវច្បាប់នៃភាគីណាមួយក្នុងជម្លោះប្រដាប់អាវុធឡើយ ។

## មាត្រា ៥

គ្មានបទបញ្ញត្តិណាមួយឡើយនៃពិធីសារនេះ អាចយកមកបកស្រាយថា ជាការរារាំងដល់ការអនុវត្តបទបញ្ញត្តិនៃច្បាប់របស់រដ្ឋភាគី ឬលិខិតុបករណ៍អន្តរជាតិ និងច្បាប់មនុស្សធម៌អន្តរជាតិ ដែលអាចមានប្រយោជន៍ច្រើនជាងនេះ ក្នុងការសម្រេចបាននូវសិទ្ធិកុមារ ។

## មាត្រា ៦

១. រដ្ឋភាគីនីមួយៗ ត្រូវចាត់វិធានការចាំបាច់ខាងផ្លូវច្បាប់ ខាងរដ្ឋបាល និងវិធានការផ្សេងទៀត ដើម្បីធានាដល់ការអនុវត្តស័ក្តិសិទ្ធិ នូវបទបញ្ញត្តិនៃពិធីសារនេះ ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

២. រដ្ឋភាគី សន្យាផ្សព្វផ្សាយគោលការណ៍ និងបទបញ្ញត្តិនៃពិធីសារនេះ និងធ្វើឱ្យមានការលើកស្ទួយតាមមធ្យោបាយសមស្រប ដល់មនុស្សពេញវ័យ និងកុមារ ។

៣. រដ្ឋភាគី ត្រូវចាត់រាល់វិធានការដែលអាចធ្វើបាន ដើម្បីធានាថា ជនរស់នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដែលជាប់កំណែន ឬប្រើក្នុងការធ្វើសង្គ្រាម ផ្ទុយពីខ្លឹមសារនៃពិធីសារនេះ ត្រូវបានរំសាយ ឬឱ្យរួចផុតពីការបម្រើទ័ព ។ បើចាំបាច់ រដ្ឋភាគីត្រូវផ្តល់ជំនួយឧបត្ថម្ភសមស្របដល់អ្នកទាំងនោះ ដើម្បីស្តារសម្បទាខាងផ្លូវកាយ និងផ្លូវចិត្តរបស់អ្នកទាំងនេះ និងដើម្បីបញ្ចូលអ្នកទាំងនោះទៅក្នុងសង្គមវិញ ។

## មាត្រា ៧

១. រដ្ឋភាគី ត្រូវសហប្រតិបត្តិការគ្នា រួមមានតាមរយៈសហប្រតិបត្តិការបច្ចេកទេស និងជំនួយឧបត្ថម្ភខាងហិរញ្ញវត្ថុផង ក្នុងការអនុវត្តពិធីសារនេះ រួមមានការបង្ការសកម្មភាព ផ្ទុយពីពិធីសារនេះ និងការស្តារនីតិសម្បទា និងការបញ្ចូលទៅក្នុងសង្គមវិញនូវជនរងគ្រោះ ពីអំពើផ្ទុយពីពិធីសារនេះ។ ជំនួយឧបត្ថម្ភ និងសហប្រតិបត្តិការនេះ នឹងត្រូវអនុម័តតាមរយៈការពិគ្រោះយោបល់ជាមួយរដ្ឋភាគី និងអង្គការអន្តរជាតិពាក់ព័ន្ធ។

២. រដ្ឋភាគី ដែលស្ថិតក្នុងនាទីផ្តល់ជំនួយឧបត្ថម្ភ ត្រូវផ្តល់ជំនួយនេះតាមរយៈកម្មវិធីពហុភាគីទ្វេភាគី ឬកម្មវិធីផ្សេងទៀតដែលមានស្រាប់ ឬពុំនោះទេ តាមរយៈមូលនិធិនៃវិភាគទានស្ម័គ្រចិត្ត ដែលបង្កើតស្របតាមបែបបទនៃមហាសន្និបាតអង្គការសហប្រជាជាតិ។

## មាត្រា ៨

១. រដ្ឋភាគីនីមួយៗ ក្នុងរយៈពេល ២ ឆ្នាំ ក្រោយពីពិធីសារនេះចូលជាធរមានសម្រាប់រដ្ឋភាគីនោះ ត្រូវដាក់របាយការណ៍មួយជូនគណៈកម្មាធិការសិទ្ធិកុមារ ដោយផ្តល់ព័ត៌មានសព្វមុខស្តី ពីវិធានការរបស់រដ្ឋភាគី ក្នុងការអនុវត្តបទបញ្ញត្តិនៃពិធីសារនេះ រួមមានវិធានការអនុវត្តបទបញ្ញត្តិស្តីពីការចូលបម្រើទ័ព និងការជ្រើសរើសទ័ពផង។

២. បន្ទាប់ពីដាក់របាយការណ៍សព្វមុខ រដ្ឋភាគីនីមួយៗ ត្រូវបញ្ចូលព័ត៌មានបន្ថែមស្តីពីការអនុវត្តពិធីសារនេះ ក្នុងរបាយការណ៍ជូនទៅគណៈកម្មាធិការសិទ្ធិកុមារ ដូចមានចែងក្នុងមាត្រា ៤៤ នៃអនុសញ្ញាសិទ្ធិកុមារ។ រដ្ឋភាគីឯទៀតនៃពិធីសារនេះ ត្រូវដាក់របាយការណ៍រៀងរាល់ ៥ ឆ្នាំម្តង។

៣. គណៈកម្មាធិការសិទ្ធិកុមារ អាចស្នើសុំឱ្យរដ្ឋភាគីផ្តល់ព័ត៌មានបន្ថែមទាក់ទងនឹងការអនុវត្តពិធីសារនេះ។

## មាត្រា ៩

១. ពិធីសារនេះ បើកចំហឱ្យចុះហត្ថលេខាសម្រាប់រដ្ឋទាំងអស់ ដែលជាភាគីនៃអនុសញ្ញា ឬដែលបានចុះហត្ថលេខាលើអនុសញ្ញា។

២. ពិធីសារនេះ ជាកម្មវត្ថុនៃការឱ្យសច្ចាប័ន និងបើកចំហដល់រដ្ឋទាំងអស់ចូលជាសមាជិក។ លិខិតុបករណ៍ឱ្យសច្ចាប័ន ឬចូលជាសមាជិក ត្រូវតំកល់ទុកនៅនឹងអគ្គលេខាធិការអង្គការសហប្រជាជាតិ។

៣. អគ្គលេខាធិការអង្គការសហប្រជាជាតិ ក្នុងឋានៈជាអ្នកទទួលទុកអនុសញ្ញា និងពិធីសារត្រូវជូនដំណឹងដល់រដ្ឋភាគីទាំងអស់នៃអនុសញ្ញា និងរដ្ឋទាំងអស់ដែលបានចុះហត្ថលេខាលើអនុសញ្ញាអំពីលិខិតុបករណ៍នៃសេចក្ដីប្រកាសនីមួយៗ ស្របតាមមាត្រា ៣ ។

## មាត្រា ១០

១. ពិធីសារនេះ ត្រូវចូលជាធរមាន ៣ ខែក្រោយពីការបានដំកល់ទុកលិខិតុបករណ៍ឱ្យសច្ចាប័ន ឬចូលជាសមាជិកទី ១០។

២. ចំពោះរដ្ឋនីមួយៗដែលឱ្យសច្ចាប័ន ឬចូលជាសមាជិកនៃពិធីសារនេះ បន្ទាប់ពីការចូលជាធរមាន ពិធីសារនេះត្រូវចូលជាធរមាន ១ ខែ បន្ទាប់ពីកាលបរិច្ឆេទដែលរដ្ឋនោះតំកល់លិខិតុបករណ៍ឱ្យសច្ចាប័ន ឬចូលជាសមាជិករបស់ខ្លួន។

## មាត្រា ១១

១. រដ្ឋភាគី អាចប្រកាសដកខ្លួនចេញពីពិធីសារនេះបានគ្រប់ពេលវេលា ដោយការជូនដំណឹងជាលាយល័ក្ខអក្សរជូនអគ្គលេខាធិការអង្គការសហប្រជាជាតិ ហើយបន្ទាប់មក អគ្គលេខាធិការត្រូវជូនដំណឹងទៅរដ្ឋភាគីផ្សេងទៀតនៃអនុសញ្ញា និងរដ្ឋទាំងអស់ដែលបានចុះហត្ថលេខាលើអនុសញ្ញា។ ការប្រកាសដកខ្លួនចូលជាធរមាន ១ ឆ្នាំបន្ទាប់ពីកាលបរិច្ឆេទដែលអគ្គលេខាធិការបានទទួលការជូនដំណឹង។ ប៉ុន្តែ បើផុតកំណត់រយៈពេល ១ ឆ្នាំនេះ រដ្ឋភាគីដែលប្រកាសដកខ្លួននោះ ជាប់ពាក់ព័ន្ធក្នុងជម្លោះប្រដាប់អាវុធ នោះការប្រកាសរំសាយនេះ មិនចូលជាធរមាន មុនចប់ជម្លោះប្រដាប់អាវុធឡើយ។

២. ការប្រកាសដកខ្លួន មិនមានអនុភាពធ្វើឱ្យរដ្ឋភាគីរួចផុតពីកាតព្វកិច្ចរបស់ខ្លួន ក្រោមពិធីសារនេះ ចំពោះអំពើណាដែលកើតមុនកាលបរិច្ឆេទនៃការប្រកាសដកខ្លួន ចូលជាធរមានឡើយ។ ការប្រកាសដកខ្លួននេះ មិនប៉ះពាល់ដោយប្រការណាមួយ ដល់ការបន្តពិនិត្យបញ្ហា ដែលកំពុងពិនិត្យដោយគណៈកម្មាធិការសិទ្ធិកុមារ មុនកាលបរិច្ឆេទនៃការប្រកាសដកខ្លួនចូលជាធរមានឡើយ។

## មាត្រា ១២

១. រដ្ឋភាគីអាចស្នើសុំធ្វើវិសោធនកម្ម និងដាក់សេចក្តីស្នើសុំនេះ ជូនអគ្គលេខាធិការអង្គការសហប្រជាជាតិ។ អគ្គលេខាធិការ ត្រូវផ្សព្វផ្សាយសំណើវិសោធនកម្មនេះដល់រដ្ឋភាគី ដោយសុំឱ្យរដ្ឋភាគីបញ្ជាក់ថាតើយល់ព្រមឱ្យមានសន្និសីទរដ្ឋភាគី ដើម្បីពិនិត្យ និងបោះឆ្នោតលើសេចក្តីស្នើសុំឬទេ។ ក្នុងរយៈពេល ៤ ខែបន្ទាប់ ផ្សព្វផ្សាយសេចក្តីស្នើសុំ បើមាន ១ ភាគ ៣ យ៉ាងតិចនៃរដ្ឋភាគីទាំងអស់ប្រកាសយល់ព្រមឱ្យមានសន្និសីទ អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវកោះប្រជុំសន្និសីទ ក្រោមការឧបត្ថម្ភរបស់អង្គការសហប្រជាជាតិ។ គ្រប់វិសោធនកម្មដែលអនុម័តដោយមតិ ភាគច្រើននៃរដ្ឋភាគីវត្តមាន និងបោះឆ្នោតក្នុងសន្និសីទ ត្រូវដាក់ជូនមហាសន្និបាតអង្គការសហប្រជាជាតិ ដើម្បីសុំការយល់ព្រម។

២. វិសោធនកម្មដែលបានអនុម័តស្របតាមកថាខណ្ឌ ១ នៃមាត្រានេះ នឹងចូលជាធរមាន នៅពេលទទួលបានការយល់ព្រមពីមហាសន្និបាតអង្គការសហប្រជាជាតិ និងទទួលបានការអនុម័តដោយមតិភាគច្រើន ២ ភាគ ៣ នៃរដ្ឋភាគី។

៣. នៅពេលដែលវិសោធនកម្មទាំងនោះចូលជាធរមានហើយ វិសោធនកម្មទាំងនោះ នឹងក្លាយជាកាតព្វកិច្ចសម្រាប់រដ្ឋភាគី ដែលព្រមទទួលយកវិសោធនកម្មទាំងនោះ រដ្ឋភាគីផ្សេងពីនេះ ត្រូវស្ថិតនៅក្រោមបទបញ្ញត្តិនៃពិធីសារនេះ និងវិសោធនកម្មមុនៗ ដែលខ្លួនបានព្រមទទួលយករួចហើយ។

## មាត្រា ១៣

១. ពិធីសារនេះដែលមានអត្ថបទជាភាសាអារ៉ាប់ ចិន អង់គ្លេស បារាំង រុស្ស៊ី និងអេស្ប៉ាញ៉ុលមានតម្លៃស្មើគ្នា និងត្រូវតំកល់ទុកនៅប័ណ្ណសារដ្ឋានរបស់អង្គការសហប្រជាជាតិ។

២. អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវបញ្ជូនច្បាប់ចម្លងនៃពិធីសារនេះ ដោយបញ្ជាក់ការចម្លងតាមច្បាប់ដើម ទៅរដ្ឋភាគីទាំងអស់នៃអនុសញ្ញា និងរដ្ឋភាគីទាំងអស់ ដែលបានចុះហត្ថលេខាលើអនុសញ្ញា។

---------//---------